A Royal Women's Hospital
Well Women's Publication

Women's Health Matters



# ខ្ញុំចង់ជួបវេជ្ជបណ្ឌិតស្រី

នៅឯ Royal Women's Hospital (មន្ទីរពេទ្យស្ត្រី) យើងយល់ថា ស្ត្រីខ្លះមានអារម្មណ៍កក់ក្ដៅជាមួយនឹងវេជ្ជបណ្ឌិតស្រី នៅពេលនិយាយអំពីការមានកូន បញ្ហាសុខភាពនៃការរួមភេទ ឬ នៅពេលដែលគេត្រូវការឲ្យមានការពិនិត្យយោនី។ ជួនកាលអ្នកនឹងជួបវេជ្ជបណ្ឌិតស្រី ប៉ុន្តែនឹងមិនអាចធ្វើដូចនេះ នៅពេលខ្លះទៀតឡើយ។

យើងបានរៀបចំប័ណ្ណពត៌មាននេះដើម្បីពន្យល់អ្នកនូវមូលហេតុដែលអ្នកនឹងមិនអាចជួបវេជ្ជបណ្ឌិតស្រីនៅគ្រប់ពេលទាំងអស់ឡើយ។

ក្រុមពិនិត្យសុខភាពរបស់យើង ត្រូវបានរៀបចំឡើងដើម្បីអាចផ្ដល់ការថែទាំយ៉ាងរហ័ស និងមានសុវត្ថិភាពទៅតាមលទ្ធភាព ជូនស្ត្រីទាំងអស់ដែលអញ្ជើញទៅកាន់មន្ទីរពេទ្យ។ បុគ្គលិកពិនិត្យសុខភាពរបស់យើងទាំងអស់ ធ្វើការផ្លាស់ប្ដូរវេនគ្នាដោយអាស្រ័យទៅលើជំនាញការនិងបទពិសោធន៍របស់ខ្លួន។

វេជ្ជបណ្ឌិតទាំងអស់ដែលប្រចាំការ មានភារកិច្ចដែលកំណត់ឲ្យធ្វើ ហើយទទួលខុសត្រូវលើការថែទាំអ្នកជម្ងឺមួយចំនួន។ នៅពេលដែលវេជ្ជបណ្ឌិតត្រូវបានហៅឲ្យទៅធ្វើការក្រៅពីភារកិច្ចជាវេនរបស់ខ្លួន អ្នកជម្ងឺរបស់វេជ្ជបណ្ឌិតនោះត្រូវតែរង់ចាំកាន់តែយូរពេលដើម្បីទទួលការថែទាំ ឬអាចថែមទាំងមានលទ្ធភាពគ្រោះថ្នាក់ដល់សុខភាពរបស់ខ្លួនទៀតផង។ អ្នកជម្ងឺទាំងអស់របស់យើងនឹងទទួលការថែទាំប្រសើរបំផុត នៅពេលដែលវេជ្ជបណ្ឌិតទាំងអស់ អាចបំពេញភារកិច្ចជាវេនរបស់ខ្លួន។ នេះមានន័យថា ជាធម្មតា យើងមិនអាចបំពេញតាមសំណូមពររបស់អ្នក ដើម្បីសុំជួបវេជ្ជបណ្ឌិតផ្សេងពីវេជ្ជបណ្ឌិតដែលត្រូវវេនថែទាំអ្នកនោះឡើយ។

វេជ្ជបណ្ឌិតទាំងអស់របស់យើង ប្រុសឬស្រី និងសិស្សរបស់យើង ត្រូវបានហ្វឹកហ្វឺនឲ្យមានការគោរព និងលាក់ការសម្ងាត់នូវពត៌មានផ្ទាល់ខ្លួនរបស់អ្នក។ នៅគ្រាសព្វថ្ងៃនេះ អ្នកទាំងនោះក៏ត្រូវបានហ្វឹកហ្វឺនយ៉ាងជាក់លាក់ផងដែរដើម្បីឲ្យយល់ដឹងនិងគោរពការបារម្ភដែលស្ត្រីខ្លះអាចមាន អំពីបញ្ហាវប្បធម៌និងភេទ។



THE ROYAL WOMEN'S HOSPITAL

**ពត៌មានទូទៅ : ខែមីនា ឆ្នាំ 2003**
**ខ្ញុំចង់ជួបវេជ្ជបណ្ឌិតស្រី (បន្ត)**

វេជ្ជបណ្ឌិតប្រុសនិងស្រីទាំងអស់របស់យើង ទទួលការហ្វឹកហ្វឺនដូចគ្នា ដូច្នេះអ្នកទាំងនេះត្រៀមខ្លួនស្មើគ្នាជាស្រេច ដើម្បីផ្តល់ជូនអ្នកនូវការថែទាំដ៏ល្អក្រៃលែង។

ផ្នែកនៃការទទួលខុសត្រូវរបស់យើងនៅឯ Royal Women's Hospital គឺការហ្វឹកហ្វឺនវេជ្ជបណ្ឌិត ឆ្មប និងអ្នកវិជ្ជាជីវៈសុខភាពឯទៀតដែលត្រូវចេញធ្វើការនៅថ្ងៃមុខ ដើម្បីឲ្យកូនអ្នកនិងអ្នកជំនាន់ក្រោយៗ នឹងទទួលការថែទាំសុខភាពល្អប្រសើរ។ នៅពេលដែលអ្នកអនុញ្ញាតឲ្យបុគ្គលិកទាំងប្រុសនិងទាំងស្រី ហើយនិងសិស្សទាំងឡាយថែទាំអ្នក នោះអ្នកកំពុងជួយធានាថា វេជ្ជបណ្ឌិតយើងទាំងអស់គ្នា ត្រូវបានហ្វឹកហ្វឺនយ៉ាងពេញលេញ។

**ជាធម្មតា** យើង**មិនអាច**បំពេញតាមសំណូមពរសុំជួបវេជ្ជបណ្ឌិតស្រី នៅក្នុងកន្លែងទាំងនេះឡើយ :

- អាគារសម្ភព
- បន្ទប់វះកាត់
- អាគារគ្រាអាសន្ន។

**ជួនកាល** យើង**មិនអាច**បំពេញតាមសំណូមពរដើម្បីជួបវេជ្ជបណ្ឌិតស្រី នៅក្នុងស្ថានការណ៍ទាំងនេះឡើយ :
- បើស្ត្រីណាមួយមាន**បញ្ហារោគដែលតម្រូវឲ្យមានការថែទាំពីគ្រូពេទ្យឯកទេស។** នេះគឺដោយសារតែវេជ្ជបណ្ឌិតយើងខ្លះ មានឋានៈខ្ពស់ជាង ហើយមានបទពិសោធន៍ច្រើនជាង នៅក្នុងផ្នែកឯកទេសជាក់លាក់។ ជាញឹកញយ វេជ្ជបណ្ឌិតទាំងនេះគឺជាបុរស។ នៅពេលខ្លះ មន្ទីរពេទ្យក៏មានវេជ្ជបណ្ឌិតតែម្នាក់គត់ដែលមានជំនាញការត្រឹមត្រូវសំរាប់សេចក្តីត្រូវការជាក់លាក់របស់អ្នកផងដែរ។
- បើអ្នកមាន**សេចក្តីត្រូវការយ៉ាងប្រញាប់**ដើម្បីឲ្យមានការណាត់ជួបឬការថែទាំ វេជ្ជបណ្ឌិតដែលត្រូវវេនផ្តល់ការថែទាំដូចនោះ អាចជាបុរស។
- បើវេជ្ជបណ្ឌិតត្រូវបានហៅឲ្យទៅព្យាបាលអ្នកជម្ងឺ**គ្រាអាសន្ន** ឬ **ឈឺមិនបានមកធ្វើការ**។
- ទោះជាជួនកាលទៅ យើងអាចបំពេញតាមសំណូមពររបស់អ្នកក្នុងការសុំជួបវេជ្ជបណ្ឌិតស្រីក្តី ក៏វាជាការសំខាន់ណាស់ដែលអ្នកត្រូវដឹងថា **យើងមិនអាចធានាផ្តល់ជូនវេជ្ជបណ្ឌិតស្រី**នៅរាល់ពេលណាត់ជួបឡើយ។

បើអ្នកមានការបារម្ភជាក់លាក់អំពីការជួបវេជ្ជបណ្ឌិតប្រុសឬស្រី អ្នកអាចធ្វើការណាត់ជួបជាមួយនឹងឆ្មប។

**ពត៌មានទូទៅ : ខែមីនា ឆ្នាំ 2003**
**ខ្ញុំចង់ជួបវេជ្ជបណ្ឌិតស្រី (បន្ត)**

បើអ្នកបានជួបប្រទះនឹងបញ្ហាណាមួយអំពីការថែទាំអ្នក ឬបើអ្នកមានមតិណាមួយអំពីវិធីដែលយើងអាចកែលំអការថែទាំរបស់យើង ឬ ការហ្វឹកហ្វឺនដែលទទួលដោយបុគ្គលិក ឬសិស្សយើង សូមពិភាក្សាបញ្ហាទាំងនេះជាមួយនឹងបុគ្គលិកម្នាក់នៃក្រុមអ្នកផ្តល់ជំនួយដល់អ្នកប្រើប្រាស់ (consumer advocate) របស់យើង។ អ្នកផ្តល់ជំនួយទាំងនេះ ស្ថិតនៅឯមន្ទីរពេទ្យដើម្បីជួយដោះស្រាយបញ្ហាណាមួយដែលអ្នកអាចមានជាមួយនឹងបុគ្គលិកមន្ទីរពេទ្យ។ សូមទូរស័ព្ទ ទៅលេខ **9344 2351** ឬ **9344 2000** ហើយសុំជួបនិយាយជាមួយនឹងអ្នកផ្តល់ជំនួយដល់អ្នកប្រើប្រាស់។

អ្នកក៏អាចទូរស័ព្ទទៅកាន់សេវា(កិច្ចបំរើ)បកប្រែភាសាផងដែរ ហើយសុំឲ្យគេជួយនិយាយទៅកាន់អ្នកផ្តល់ជំនួយដល់អ្នកប្រើប្រាស់។ សូមទូរស័ព្ទទៅលេខ **9344 2245** ។